ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៣២០ ប្រក.កសក

# ប្រកាស
# ស្តីពី
# ការបង្កើតដែនជម្រកសុវត្ថិភាពត្រែងឈាម
# នៅភូមិព្រែកស្វែង ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាន នៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកសិកម្ម ... ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងបង្កើតដែនជម្រកសុវត្ថិភាពគ្រែងឈាម ដើម្បីការពារ អភិរក្ស និងប្រើប្រាស់ប្រភេទគ្រែងឈាមឱ្យមាននិរន្តរភាព ស្របតាមគោលនយោបាយវិស័យជលផលជាតិ ក្នុងការចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់លើដែនជម្រកសុវត្ថិភាពគ្រែងឈាម ដែលមានផ្ទៃក្រឡាសរុប១១៦ (មួយរយដប់ប្រាំមួយ) ហិកតា ស្ថិតនៅភូមិព្រែកសង្កែ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

ផែនទីនិងនិយាមកាដែនជម្រកសុវត្ថិភាពគ្រែងឈាមត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣.-**

ហាមឃាត់ការធ្វើនេសាទគ្រែងឈាមក្នុងដែនជម្រកសុវត្ថិភាពគ្រែងឈាមចាប់ពីថ្ងៃទី០១ ខែមិថុនា ដល់ថ្ងៃទី៣១ ខែតុលា ជារៀងរាល់ឆ្នាំ លើកលែងតែសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រជលផល ដែលត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋបាលជលផល។ ក្នុងរយៈពេលហាមឃាត់នេះ រាល់ការធ្វើនេសាទប្រភេទផ្សេងទៀតនៅក្នុងដែនជម្រកសុវត្ថិភាពគ្រែងឈាមដែលធ្វើឱ្យប៉ះពាល់ដល់ជម្រកគ្រែងឈាមឬប្រព័ន្ធអេកូឡូស៊ី មិនត្រូវបានអនុញ្ញាត។

**ប្រការ៤.-**

ក្រៅពីរយៈពេលហាមឃាត់ដូចក្នុងប្រការ៣ខាងលើ ការធ្វើនេសាទគ្រែងឈាមនៅក្នុងដែនជម្រកសុវត្ថិភាពនេះអាចអនុញ្ញាតបានដោយដៃប៉ុណ្ណោះ។ រាល់ការធ្វើនេសាទប្រភេទផ្សេងៗក្រៅពីគ្រែងឈាមអាចអនុញ្ញាតស្របតាមច្បាប់និងបទប្បញ្ញត្តិនានាជាធរមាន។

**ប្រការ៥.-**

ការគ្រប់គ្រងដែនជម្រកសុវត្ថិភាពគ្រែងឈាម ស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋបាលជលផលនិងរដ្ឋបាលខេត្តព្រះសីហនុ ដែលមានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះសីហនុជាសេនាធិការផ្ទាល់ ដោយមានការចូលរួមពីសហគមន៍នេសាទ សមត្ថកិច្ចពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា។

**ប្រការ៦.-**

ភារកិច្ចសំខាន់ៗមានដូចខាងក្រោម៖

- បង្កើតយន្តការគ្រប់គ្រង
- រៀបចំនិងអនុម័តផែនការគ្រប់គ្រង
- រៀបចំក្រុមល្បាតនិងអនុវត្តសកម្មភាពល្បាតជាប្រចាំ
- កំណត់និងបោះបង្គោលព្រំប្រទល់និងដាក់ស្លាកសញ្ញា
- សិក្សាស្រាវជ្រាវបច្ចេកទេស អង្កេតតាមដានលក្ខណៈជីវសាស្ត្រ និងផលស្តុកគ្រែងឈាមក្នុងធម្មជាតិ
- អប់រំនិងផ្សព្វផ្សាយដល់ប្រជានេសាទនិងអ្នកពាក់ព័ន្ធផ្សេងៗអំពីសារប្រយោជន៍ជម្រកសុវត្ថិភាពគ្រែងឈាម។

**ប្រការ៧.-**

ប្រភពថវិកាសម្រាប់ការងារបង្កើតនិងគ្រប់គ្រងដែនជម្រកសុវត្ថិភាពគ្រែងឈាមមានជាអាទិ៍៖

- ថវិកាជាតិ
- ដៃគូអភិវឌ្ឍន៍ ឬសប្បុរសជននានា
- ចំណូលផ្សេងៗ។

**ប្រការ៨.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

អគ្គលេខាធិការ អគ្គាធិការ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១០ កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះសីហនុ
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ............ប្រក.កសក ចុះថ្ងៃទី........ខែ...........ឆ្នាំ២០២០ ស្តីពីការបង្កើតដែនជម្រកសុវត្ថិភាពក្រែងឈាម នៅភូមិព្រែកសង្កែ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ




**កំណត់សម្គាល់**

- ● ទីតាំងបង្គោលព្រំប្រទល់ដែនជម្រកសុវត្ថិភាពក្រែងឈាម
- ● ទីតាំងភូមិ
- ◐ ទីតាំងឃុំ
- ▭ ព្រំប្រទល់ដែនជម្រកសុវត្ថិភាពក្រែងឈាម
- ទំនាបបឹង ព្រៃកោងកាង

**និយាមកា**

| ID | UTM_X | UTM_Y |
|---|---|---|
| 1 | 379511 | 1175060 |
| 2 | 380063 | 1175193 |
| 3 | 380603 | 1175323 |
| 4 | 380821 | 1174795 |
| 5 | 381045 | 1174253 |
| 6 | 380432 | 1174142 |
| 7 | 379819 | 1174031 |
| 8 | 379665 | 1174546 |

ជើង
លិច កើត
ត្បូង

មាត្រដ្ឋាន ១:៤០.០០០

0 1 គ.ម